**DOMESTIC VIOLENCE AFFIDAVIT**

***លិខិតបញ្ជាក់***

***អំពើហិង្សាក្នុងគ្រួសារ***

____________________________________

(Party name as displayed in case caption)
*(ឈ្មោះភាគី ដូចបង្ហាញក្នុងចំណងជើងរឿងក្តី)*

Vs./ *ទល់នឹង*

____________________________________

(Party name as displayed in case caption)
*(ឈ្មោះភាគី ដូចបង្ហាញក្នុងចំណងជើងរឿងក្តី)*

______________________________

Docket/Case No.
*សំណុំរឿង/រឿងក្តីលេខ*

______________________________

Court
*តុលាការ*

Pursuant to Pa.R.C.P.M.D.J. No. 514.1:

I,________________________________, the undersigned, certify and declare as follows:

1) I am a victim of domestic violence.
2) The name of the perpetrator of domestic violence: ________________________
3) The perpetrator’s relationship to me is: ________________________________
4) Docket number(s) (if applicable) of any protection from abuse case involving me and the perpetrator:

ស្របតាម Pa.R.C.P.M.D.J. លេខ 514.1៖

ខ្ញុំ ________________________________ ជាហត្ថលេខី សូមបញ្ជាក់និងអះអាងដូចខាងក្រោម៖

1) ខ្ញុំគឺជាជនរងគ្រោះម្នាក់នៃអំពើហិង្សាក្នុងគ្រួសារ។
2) ឈ្មោះរបស់ចារីនៃអំពើហិង្សាក្នុងគ្រួសារគឺ៖ ________________________
3) ទំនាក់ទំនងរវាងចារីនិងខ្ញុំគឺ៖ ________________________________
4) លេខសំណុំរឿង (បើមាន) នៃការការពារពីករណីរំលោភបំពាន ពាក់ព័ន្ធជាមួយខ្ញុំនិងចារី៖

I verify that the statements herein are true and correct. I understand that false statements herein are made subject to the penalties of Section 4904 of the Crimes Code (18 Pa. C.S. § 4904) relating to unsworn falsification to authorities.

ខ្ញុំសូមបញ្ជាក់ថា សេចក្តីថ្លែងនៅទីនេះគឺពិតនិងត្រឹមត្រូវ។ ខ្ញុំដឹងថា រាល់សេចក្តីថ្លែងការណ៍មិនពិតគឺជាកម្មវត្ថុនៃការពិន័យយោងតាមមាត្រា 4904 នៃក្រមព្រហ្មទណ្ឌ (18 Pa. C.S. § 4904) ពាក់ព័ន្ធនឹងការផ្តល់នូវសក្ខីកម្មក្លែងក្លាយដល់អាជ្ញាធរ។

I certify that this filing complies with the provisions of the Case Records Public Access Policy of the Unified Judicial System of Pennsylvania that require filing confidential

ខ្ញុំសូមបញ្ជាក់ថា ការដាក់ឯកសារនេះអនុលោមតាមបទបញ្ញត្តិនៃគោលការណ៍ទទួលជាសាធារណៈនូវកំណត់ត្រារឿងក្តី របស់ប្រព័ន្ធតុលាការរួមនៃរដ្ឋ Pennsylvania ដែលតម្រូវឲ្យដាក់ព័ត៌មាននិងឯកសារ

information and documents differently than non-confidential information or documents.

សម្ងាត់ដាច់ដោយឡែកពីព័ត៌មានឬឯកសារមិនសម្ងាត់។

Signature/*ហត្ថលេខា*៖

Date/*កាលបរិច្ឆេទ*៖

## Supplemental Instructions

## សេចក្តីណែនាំបន្ថែម

A victim of domestic violence is "a person who has obtained a protection from abuse order against another individual or can provide other evidence of abuse." See Pa.R.C.P.M.D.J. No. 1001(10); 68 P.S. 250.513. A tenant who is aggrieved by a judgment for the delivery of real property arising out of a residential lease and who is a victim of domestic violence may appeal the judgment within 30 days after the date of the entry of judgment by filing a notice of appeal with the prothonotary/clerk of court of the court of common pleas, civil division, along with a copy of the Domestic Violence Affidavit. A tenant who is a victim of domestic violence may file the Affidavit with the magisterial district court to stay the execution of an order for possession pursuant to Rule 514.1 prior to filing an appeal with the court of common pleas. If the Affidavit is filed with the magisterial district court, the tenant should attach a copy of the Affidavit to the notice of appeal. If the tenant does not file the Domestic Violence Affidavit with the magisterial district court or does not appeal to the court of common pleas within 21 days following the entry of the judgment, the tenant is at risk of eviction.

ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារគឺជា "បុគ្គលដែលបានទទួលការការពារពីការរំលោភបំពានពីបុគ្គលមួយទៀត ឬក៏អាចផ្តល់ភស្តុតាងផ្សេងទៀតនៃការរំលោភបំពាន"។ សូមមើល Pa.R.C.P.M.D.J. លេខ 1001(10); 68 P.S. 250.513។ អ្នកជួលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចឲ្យប្រគល់អចនលទ្រព្យ ដោយសារការជួលទីលំនៅ និងជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អាចប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះក្នុងពេល 30 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសាលក្រមនោះ តាមរយៈការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ជាមួយនាយកក្រឡាបញ្ជី/ក្រឡាបញ្ជីនៃតុលាការ common pleas ផ្នែករដ្ឋប្បវេណី ជាមួយនឹងសំណៅចម្លងនៃលិខិតបញ្ជាក់អំពីអំពើហិង្សាក្នុងគ្រួសារ។ អ្នកជួលដែលជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារអាចដាក់លិខិតបញ្ជាក់នេះនៅតុលាការស្រុកមានសមត្ថកិច្ច ដើម្បីរក្សាការអនុវត្តដីកាបញ្ជាសម្រាប់ការកាន់កាប់ ស្របតាមវិធាន 514.1 មុនពេលដាក់បណ្តឹងឧទ្ធរណ៍នៅតុលាការ Common Pleas។ បើលិខិតបញ្ជាក់នេះត្រូវបានដាក់នៅតុលាការស្រុកមានសមត្ថកិច្ច អ្នកជួលគួរភ្ជាប់សំណៅចម្លងនៃលិខិតបញ្ជាក់នេះជាមួយនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍។ បើអ្នកជួលមិនដាក់លិខិតបញ្ជាក់អំពីអំពើហិង្សាក្នុងគ្រួសារនៅតុលាការស្រុកមានសមត្ថកិច្ច ឬក៏មិនប្តឹងឧទ្ធរណ៍ទៅតុលាការ Common Pleas ក្នុងពេល 21 ថ្ងៃ បន្ទាប់ពីការចេញសាលក្រមទេ អ្នកជួលនឹងប្រឈមហានិភ័យនៃការបណ្តេញចេញ។

This Domestic Violence Affidavit is not a public record and it shall not be publicly accessible.

លិខិតបញ្ជាក់អំពីអំពើហិង្សាក្នុងគ្រួសារនេះមិនមែនជាកំណត់ត្រាសាធារណៈទេ ហើយក៏មិនអាចទទួលជាសាធារណៈដែរ។